២-ធ្វើរបាយការណ៍អំពីលទ្ធផលត្រួតពិនិត្យ និងស្នើវិធានការដោះស្រាយ ដើម្បីដាក់ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

ប្រការ ៣ : សមាជិកគណៈកម្មការអន្តរក្រសួងត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។

ប្រការ ៤ : បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវទុកជានិរាករណ៍ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តសៀមរាប និងសមាសភាពដូចមានរាយនាមក្នុងប្រការ១ ត្រូវអនុវត្តន៍ សេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

***

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០០

## សេចក្តីសំរេច ១១ សសរ

### ស្តីពី ការបង្កើតគណៈកម្មការចំរុះ ដោះស្រាយបញ្ហាដីធ្លី និងគ្រួសារ ប្រជាជនស្នាក់នៅបរិវេណអតីត ម៉ូតែលសុខា ក្រុងព្រះសីហនុ

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងសេចក្តីជូនដំណឹង របស់ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៦១២ សជណ ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ១៩៩៦ ស្តីពីការអនុញ្ញាតអោយក្រសួងទេសចរណ៍ បានចុះកិច្ចព្រមព្រៀងជាមួយក្រុមហ៊ុនវិនិយោគទុន សូគីម៉ិចកម្ពុជា

-យោងកិច្ចសន្និបាតរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍តំបន់អតីតម៉ូតែលសុខា ចុះថ្ងៃទី ២០ ខែ តុលា ឆ្នាំ ១៩៩៩ រវាងក្រសួងទេសចរណ៍ (តំណាងរាជរដ្ឋាភិបាល) និងក្រុមហ៊ុនមីនីអេកគ្រុបខេមបូឌា

-យោងតាមសំណើរបស់ក្រសួងទេសចរណ៍

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការចំរុះដោះស្រាយបញ្ហាដីធ្លី និងផ្តល់ការប្រជាជនស្នាក់នៅក្នុងបរិវេណអតីតម៉ូតែលសុខា ក្រុងព្រះសីហនុ មានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម ថោង ខុន | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | ប្រធាន |
| ២-ឯកឧត្តម ស្មោន សារិន | អភិបាលរងទី១ ក្រុងព្រះសីហនុ | អនុប្រធាន |
| ៣-ឯកឧត្តម ញឹម ខេមរា | អនុប្រធានទី១ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | ជាសមាជិកអចិន្ត្រៃយ៍ |
| ៤-លោក យ៉ា ឡេងហាក់ | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ជាសមាជិក |
| ៥-លោក យូ ម៉េង | តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក សូ សុខ | ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និង សុរិយោដីក្រុងព្រះសីហនុ | សមាជិក |
| ៧-លោក តេង ហ៊ុយ | ប្រធានមន្ទីរទេសចរណ៍ក្រុងព្រះសីហនុ | សមាជិក |
| ៨-លោក សុខ តុងហាប់ | នាយការិយាល័យគណនេយ្យនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ | ជាសមាជិក |
| ៩-លោក សំ ទុន្ធា | នាយរងការិយាល័យរដ្ឋបាលក្រសួងទេសចរណ៍ | សមាជិក |

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច ចុះត្រួតពិនិត្យ វាយតម្លៃនូវការពាក់ព័ន្ធអំពីបញ្ហាដីធ្លី និងផ្តល់ការប្រជាជនស្នាក់នៅក្នុងបរិវេណអតីតម៉ូតែលសុខា ក្រុងព្រះសីហនុ ដើម្បីលើកសំណើជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងទេសចរណ៍ ។

ប្រការ ៤ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំ និងអនុវត្តការងារតាមការកំណត់របស់ប្រធានគណៈកម្មការ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អភិបាលក្រុងព្រះសីហនុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន និងស្ថាប័នពាក់ព័ន្ធ

ប្រមាថឯកភាពផង ដែលមានតែមួយប្រការៗ ត្រូវទទួលការព្រមានអនុវត្តពីក្រសួងតាមប្រកាសនេះ ដោយមាន ប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## III- ការងារបណ្តាក្រសួង

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០

### ទីស្តីការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

### ប្រកាស លេខ ៧៥ ឧរថ.ប្រក

### ស្តីពី ការបង្កើត លទ្ធកម្មសាធារណៈ របស់ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

***

### រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តមសីហនុ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

-បានឃើញអនុក្រឹត្យលេខ៣៥ អនក្រ-បក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្មរ៉ែនិងថាមពល

-បានឃើញអនុក្រឹត្យលេខ៦០ អនក្រ/បក ចុះថ្ងៃទី ៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញសារាចរណែនាំ លេខ ០០៦ សហវ.សហរ.សរ ចុះថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តវិធាន និងបែបបទក្នុងការគ្រប់គ្រងលទ្ធកម្មសាធារណៈ

-បានឃើញការចាំបាច់របស់ក្រសួង